ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

អគ្គនាយកដ្ឋានរដ្ឋបាល

លេខ: ២០៨៥.សរឃ

រដ្ឋបាលខេត្តប៉ៃលិន
លេខ: ៣៣០៥ ៩
ថ្ងៃទី ៣០ ខែ ០៦ ម៉ោង ៤:២៥
បញ្ជូនទៅ:

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការសិក្សាថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររង បង់ថ្លៃ របស់សាកលវិទ្យាល័យត្រាវិញ សម្រាប់ឆ្នាំ២០១៧-២០១៨ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

**យោង** : លិខិតលេខ៨៤ អយក.សជណ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម** មេត្តាជ្រាបថា សាកលវិទ្យាល័យត្រាវិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាមនឹងធ្វើការជ្រើសរើស និស្សិត និងមន្ត្រីរាជការ ដែលមានបំណងចង់សិក្សាថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្ររង បង់ថ្លៃនៅសាកលវិទ្យាល័យត្រាវិញ សម្រាប់ឆ្នាំសិក្សា២០១៧-២០១៨។ ចំពោះពេលវេលាសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្រសិក្សាពេញម៉ោងមានរយៈពេល០៥ឆ្នាំ ថ្នាក់បរិញ្ញាបត្ររងមានរយៈពេល០៤ឆ្នាំ និងជំនាញបសុពេទ្យមានរយៈពេល០៦ឆ្នាំ ដែលតម្លៃសិក្សាក្នុងមួយឆ្នាំចាប់ពី៦៨០ដុល្លារហូតដល់១៣៧០ដុល្លារ ទៅតាមមុខវិជ្ជាឯកទេស និងកម្រិតសិក្សាដែលបេក្ខជនជ្រើសរើស។ ចំពោះការចំណាយលើការស្នាក់នៅ និងការហូបចុកត្រូវចំណាយប្រមាណ១២០ដុល្លារទៅ១៥០ដុល្លារ ក្នុងមួយខែ។ បេក្ខជនតម្រូវឱ្យសិក្សាភាសាវៀតណាមរយៈពេល០១ឆ្នាំមុននឹងសិក្សាទៅលើជំនាញរបស់ខ្លួន។

សម្រាប់ព័ត៌មានលម្អិត និងលក្ខខណ្ឌជ្រើសរើសផ្សេងៗមានដូចខាងក្រោម ៖

**ក. លក្ខណសម្បត្តិដើម្បីដាក់ពាក្យ**

- មានសញ្ជាតិខ្មែរ
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានសុខភាពល្អទាំងកាយសម្បទា និងសតិបញ្ញា

**ខ. មុខជំនាញសិក្សា**

- **ថ្នាក់បរិញ្ញាបត្រ**

០១. គណនេយ្យ
០២. ហិរញ្ញវត្ថុ-ធនាគារ
០៣. គ្រប់គ្រងពាណិជ្ជកម្ម
០៤. សេដ្ឋកិច្ច
០៥. នីតិសាស្ត្រ
០៦. កសិកម្ម
០៧. ភាសាអង់គ្លេស
០៨. អប់រំមត្តេយ្យ
០៩. ព័ត៌មានវិទ្យា
១០. បច្ចេកវិទ្យាសាងសង់
១១. បច្ចេកវិទ្យាអគ្គិសនី-អេឡិចត្រូនិក
១២. បច្ចេកវិទ្យាគីមីសាស្ត្រ
១៣. បច្ចេកវិទ្យាមេកានិក
១៤. សុខាភិបាលសាធារណៈ
១៥. តេស្តវេជ្ជសាស្ត្រ
១៦. បសុពេទ្យ
១៧. ថែទាំជម្ងឺ
១៨. ឱសថសាស្ត្រ
១៩. ពហុវេជ្ជសាស្ត្រ
២០. ទន្តសាស្ត្រ

❖ **ថ្នាក់បរិញ្ញាបត្ររង**

០១. គណនេយ្យ
០២. គ្រប់គ្រងពាណិជ្ជកម្ម
០៣. ព័ត៌មានវិទ្យា
០៤. វៀតណាមវិទ្យា (ជំនាញទេសចរណ៍)
០៥. បច្ចេកវិទ្យាសាងសង់សំណង់
០៦. អប់រំមត្តេយ្យ
០៧. អេឡិចត្រូនិក
០៨. បច្ចេកវិទ្យាអគ្គិសនី
០៩. បច្ចេកវិទ្យាមេកានិក
១០. តេស្តវេជ្ជសាស្ត្រ
១១. បសុពេទ្យ
១២. ថែទាំជម្ងឺ
១៣. ឱសថ
១៤. ភាសាអង់គ្លេស

**គ. កាលបរិច្ឆេទ និងព័ត៌មានលម្អិត**

ចំពោះមន្ត្រីរាជការ និងបេក្ខជនដែលមានបំណងចង់ដាក់ពាក្យចូលរៀននៅសាកលវិទ្យាល័យខាងលើ អាចទំនាក់ទំនងទៅកាន់លោក **ថាច់ ច័ន្ទសុឃុំ** តាមរយៈទូរស័ព្ទលេខ+៨៤១៦៧៥០៨០៨៧៥ ឬ +៨៥៥៧១៨០៣៩៥៥៤ ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទទួលទូលាយតាមការគួរ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

**ប្រាក់ សំអឿន**

<u>សូមទំនាក់ទំនង៖</u>
- លោក ងួន គីមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧